# ចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ COVID-19 នៅតំបន់ King County





**ថ្នាំវ៉ាក់សាំងកូវីដ-១៩ ត្រូវបានផ្តល់ជូនដោយមិនគិតថ្លៃ**
និងអាចរកបានដោយមិនគិតពីការធានារ៉ាប់រងសុខភាព សញ្ជាតិ
ឬស្ថានភាពអន្តោប្រវេសន៍នោះទេ។



**សួរអ្នកផ្តល់សេវាសុខភាពរបស់អ្នកថាតើអ្នកត្រូវការចាក់ប៉ុន្មានដង។**
ដើម្បីចាក់ឱ្យបានគ្រប់ចំនួន យើងត្រូវចាក់ថ្នាំវ៉ាក់សាំង Moderna និង Pfizer
ឱ្យបានចំនួន ២ ដង ដែលឃ្លាតពីគ្នា ៣ ទៅ ៤ សប្តាហ៍ ចំណែកវ៉ាក់សាំងចនសុន &
ចនសុន ត្រូវការចាក់តែមួយដងប៉ុណ្ណោះ។ អ្នកដែលមានហានិភ័យខ្ពស់
ក៏អាចចាក់ដូសជំរុញបន្ថែមទៀតដែរ។



**វ៉ាក់សាំងកូវីដ-១៩ មានសុវត្ថិភាពនិងប្រសិទ្ធភាពខ្លាំងណាស់។** វ៉ាក់សាំងកូវីដ-១៩
ទាំងអស់ត្រូវតែឆ្លងកាត់ការធ្វើតេស្ត និងវាយតម្លៃយ៉ាងហ្មត់ចត់មុន
នឹងអាចប្រើប្រាស់បាន។ រដ្ឋបាលត្រួតពិនិត្យចំណីអាហារនិងឱសថរបស់សហរដ្ឋអាមេរិក
(FDA) បានអនុញ្ញាតអោយយកវ៉ាក់សាំងមកប្រើការជាបន្ទាន់ហើយមិនទាន់
បានឃើញកើតបញ្ហាសុវត្ថិភាពធ្ងន់ធ្ងរទេ។ អ្នកជំនាញឯករាជ្យក៏បានបញ្ជាក់ថា
វាស្របត្រឹមត្រូវតាមស្តង់ដារសុវត្ថិភាពនិងប្រសិទ្ធភាពខ្ពស់។



**អ្នកអាចមានអារម្មណ៍ថាមានផលប៉ះពាល់។** ដូចគ្នានឹងថ្នាំវ៉ាក់សាំងផ្សេងៗដែរ
អ្នកអាចឈឺដៃ ក្តៅខ្លួន ឈឺក្បាល ឬអស់កម្លាំងបន្ទាប់ពីបានចាក់វ៉ាក់សាំងរួច។
ទាំងនេះគឺជា
សញ្ញាបង្ហាញថាប្រព័ន្ធភាពស៊ាំនៃរាងកាយរបស់អ្នកកំពុងបង្កើតការការពារ។

**សិក្សាពីអ្វីដែលអ្នកអាចធ្វើបានបន្ទាប់ពីចាក់វ៉ាក់សាំងរួច។**
នៅពេលអ្នកចាក់វ៉ាក់សាំងបានពេញលេញអ្នកអាច៖

- ទៅលេងក្នុងផ្ទះជាមួយមនុស្សដែលចាក់វ៉ាក់សាំងពេញលេញដោយគ្មានម៉ាស់ (លើកលែងតែមានមនុស្សច្រើននិងនៅទីសាធារណៈ)
- ធ្វើដំណើរដោយមិនត្រូវបានធ្វើតេស្តកូវីដ-១៩ (COVID-19)

ប៉ុន្តែយើងកំពុងសិក្សាថាតើវ៉ាក់សាំងការពារការរីករាលដាលនៃកូវីដ-១៩ (COVID-19)
បានល្អប៉ុនណា។ សូមជៀសវាងជួបជុំមនុស្សច្រើន។ ពាក់ម៉ាស់ហើយនៅដាច់ឆ្ងាយពីគ្នា ៦ ហ្វីត (២ ម៉ែត្រ)
នៅពេលដែលអ្នកនៅជាមួយមនុស្សដែលគ្មានវ៉ាក់សាំងដែលមានហានិភ័យខ្ពស់។
ស្វែងយល់បន្ថែម៖ KingCounty.gov/aftervaccine/khmer ។

Khmer_10.29.21

Public Health
Seattle & King County

# វិធីដើម្បីទទួលបានវ៉ាក់សាំង

អ្នកដែលមានអាយុចាប់ពី 5 ឆ្នាំឡើងទៅមានសិទ្ធិទទួលការចាក់វ៉ាក់សាំង។ ប្រសិនបើអ្នកមានអាយុ 5-17 ឆ្នាំ អ្នកអាចទទួលបានវ៉ាក់សាំង Pfizer តែប៉ុណ្ណោះ។

ជម្រើសសម្រាប់ការដាក់ណាត់ជួបៈ

១) **ជ្រើសរើសទីតាំងនៅ King County ពីបញ្ជីរបស់យើង។**
**ទីតាំងជាច្រើនមិនត្រូវការការណាត់ជួបទេ!** ចូលទៅកាន់ Kingcounty.gov/vaccine/khmer
ឬប្រើកាមេរ៉ារបស់ទូរស័ព្ទទំនើបដើម្បីស្កេនលេខកូដ QR នេះៈ

២) ទៅរកឱសថស្ថាន ឬកន្លែងផ្សេងទៀតដោយប្រើ**ទីតាំងវ៉ាក់សាំង**របស់រដ្ឋវ៉ាស៊ីនតោន
(Washington State's **Vaccine Locator**)
(ជ្រើសរើសភាសានៅលើម៉ឺនុយទម្លាក់ចុះក្រោមនៅជ្រុងលើខាងស្តាំ)ៈ
Vaccinelocator.doh.wa.gov

**៣) តើអ្នកត្រូវការជំនួយក្នុងការដាក់ណាត់ជួបចាក់វ៉ាក់សាំងតាមទូរស័ព្ទឬទេ?**
សូមទូរស័ព្ទមកមជ្ឈមណ្ឌលទូរស័ព្ទរបស់ King County ទទួលបន្ទុកជំងឺកូវីដ-១៩
នៅថ្ងៃណាក៏បានពីម៉ោង ៨ ព្រឹកដល់ ៧ ល្ងាចតាមលេខ 206-477-3977 ។
មានអ្នកបកប្រែភាសា- សូមនិយាយប្រាប់ភាសារបស់អ្នកនៅពេលគេភ្ជាប់ទូរស័ព្ទ។

សម្រាប់ព័ត៍មានបន្ថែម ៖ kingcounty.gov/covid/vaccine/khmer

# ការធ្វើដំណើរទៅកាន់ទីតាំងចាក់វ៉ាក់សាំងរបស់អ្នក

- សម្រាប់ជំនួយតាមទូរស័ព្ទ
  សូមទូរស័ព្ទទៅកាន់បណ្តាញជំនួយការសម្របសម្រួលការធ្វើដំណើរទៅចាក់វ៉ាក់សាំងតាមលេខ **425-943-6706 ពីថ្ងៃច័ន្ទដល់ថ្ងៃសុក្ររវាងម៉ោង 8:30ព្រឹកដល់ម៉ោង 4:00 ល្ងាច។ ចុចលេខ 5 សម្រាប់ការបកប្រែភាសា។** អ្នកក៏អាចទុកសារជាសំឡេងហើយគេនឹងខលមកវិញ។
  សូមទូរស័ព្ទមកយ៉ាងហោចណាស់ ៦០នាទីមុនពេលអ្នកត្រូវការជិះ។
- ដើម្បីស្នើសុំការដឹកជញ្ជូនសម្រាប់មនុស្សច្រើនអ្នក សូមចូលមើល
  (មានតែភាសាអង់គ្លេសប៉ុណ្ណោះ)៖ bit.ly/vaxride
- ដើម្បីស្វែងយល់អំពីជម្រើសនៃការធ្វើដំណើរ រួមទាំងសម្រាប់មនុស្សចាស់ ជនពិការ
  អ្នកទទួលជំនួយពី Medicaid និងទាហាន សូមចូលមើលៈ FindARide.org/COVID



Public Health
Seattle & King County